# ដាំដើមឈើ




## ដំណើររឿងរបស់អ្នកថែរក្សាបរិស្ថាន

ប្រទេសកម្ពុជា:
សប្តាហ៍សុខដុមរមនានៃអន្តរសាសនា

ពីមិត្តសំលាញ់ **អន្តរសាសនាដើម្បីបរិស្ថាន**
ដែលជាអ្នកថែរក្សាសម្រាប់ការបង្កើត

## មាតិកា

១) សេចក្ដីផ្ដើម (ឌេនីស ខតឡែន-Denise Coghlan rsm)...........០១
២)សហប្រតិបត្តិការ អន្តរសាសនា សម្រាប់ ការអភិវឌ្ឍ......០២
ប្រកបដោយនិរន្តរភាព (អឺន យូចេនសិន-Ernst Jurgensen)
៣)ប្លាស្ទិចអាចសម្លាប់បរិស្ថានរបស់យើង............................០៤
(អុក ភិរម្យ, តូរី ឌួស-Tori Duoos)
៤) បម្រែបម្រួលអាកាសធាតុ (ស្រី សុខ)...................................០៦
៥) ព្រៃឈើកម្ពុជាផ្ដល់ជីវិតដល់ប្រទេសកម្ពុជា.......................០៨
៦) សុភមង្គល និងបរិស្ថាន (បប់ ម៉ាត-Bob Maat)......................១០
៧) ត្រីគល់រាំងនៅមានជីវិត(ហ្គាព្រីអែល-Fr.Gabriel).............១២
៨) និមិត្តរូប "ដើមឈើផ្ដល់ជីវិត"..............................................១៥
៩) បិទផ្ទិតចន្លោះ: ជួយមាតាធម្មជាតិដោយធ្វើជីកំប៉ុស្ត..........១៦
១០) សិក្ខាសាលាទី១របស់យើង(១១-១៥ ធ្នូ ២០១២)...............១៨

សូមថ្លែងអំណរគុណដល់ សាក់ សុភ័ក្រ្ត តូរី ឌួស(Tori Duoos) និង បងស្រី ឌេនីស ខតឡែន (Sr. Denise Coghlan) ដែលបានចងក្រង សៀវភៅតូចនេះឡើង ។
ហើយក៏សូមថ្លែងអំណរគុណផងដែរចំពោះអ្នកដែលបានចែករំលែក រឿងរ៉ាវ និង សិក្ខាកាម ដែលបានចូលរួមសិក្ខាសាលា "អន្តរសាសនា" នៅមណ្ឌលមេត្តា ករុណាសៀមរាប ។

កម្មវិធី **អន្តរសាសនា** និង **សៀវភៅតូច** នេះ ទទួលបានការគាំទ្រពី អង្គការមេត្តា ករុណាសម្រាប់ជនភៀសខ្លួន (JRS) និង អង្គការដានមិសសិន (Danmission) ។

# សេចក្ដីផ្ដើម

*នៅខែមិថុនាឆ្នាំ ២០១៣ កន្លងទៅនេះ បងប្អូនជា ពុទ្ធសាសនិក គ្រីស្តសាសនិក អ៊ីស្លាមសាសនិក និងក្រុមប្រជាជនជាតិភាគតិចជាច្រើននាក់ បានជួបប្រជុំគ្នា នៅមណ្ឌលមេត្តា ករុណា ខេត្តសៀមរាប ៖*

- *ដើម្បីស្វែងរកថា តើសាសនារបស់គាត់ ណែនាំយ៉ាងដូចម្ដេចខ្លះ ចំពោះពួកគាត់ ក្នុងការថែរក្សាបរិស្ថាន ។*
- *ដើម្បីស្វែងយល់អំពី ដំណើររឿងល្អៗក្នុងស្រុក ស្តីអំពីបរិស្ថាននៃប្រទេសកម្ពុជា ។*
- *ធ្វើគម្រោងសកម្មភាព ដើម្បីថែរក្សាសម្រាប់ការបង្កើតថ្មី ។*

*ដំណើររឿង នៅក្នុងសៀវភៅនេះ គឺជាសមិទ្ធផលមួយនៃសិក្ខាសាលានេះ។ ពួកយើង ទទួលបានការជំរុញទឹកចិត្តដោយ លោក ណៅ សុខ គាត់ជាអ្នកដែលបាន និងកំពុងដាំដើមឈើ នៅគ្រប់ទីកន្លែងទូទាំងប្រទេសកម្ពុជា ។ លោក សុខ បាន ទទួលការជំ រុ ញទឹកចិត្ត ក្នុងការចាប់ផ្តើមដាំដើមឈើបន្ទាប់ពី គាត់ បានឃើញ រូបភាពនៃ ប្រ ជាជន ខ្វះអាហារទទួលទាន នៅទីបរអាព្រិច ដែលបណ្តាលមកពី ភាពរាំងស្ងួតដោយសារគ្មានដើមឈើ ។ ប្រទេសកម្ពុជា អាចនឹងមានទុក្ខវេទនា ដូចគ្នានេះដែរ ។*

*ពាក្យប្រាជ្ញមួយចំនួន ដែលបានមកពីសិក្ខាសាលានេះគឺ៖*
**ដាំឈើប្រាំដើម នាំគ្នាល្បី កាប់ឈើពេញដីនាំគ្នាស្លាត់ ។** *( ក្រុមប្រជាជនជាតិភាគតិច)*
**ការញញឹម ជាការធ្វើទាន ។ ដាំដើមឈើ ជាការធ្វើទាន ដែលមានអាយុកាលយូរជាងការញញឹម ។** *(អ៊ីស្លាមសាសនិក)*
**ព្រៃឈើ គឺជាអំណោយរបស់ព្រះជាម្ចាស់ ។ សូមអរ ព្រះគុណ ។** *(គ្រីស្តសាសនិក)*
**ចង់ស្បង់ជីពរ ដើម្បីការពារព្រៃឈើ ។** *(ពុទ្ធសាសនិក)*

*យើង សង្ឃឹមថាលោកអ្នក នឹងចូលចិត្តដំណើររឿងទាំងនេះ ហើយនិង ថែមទាំងជួយជម្រុញទឹកចិត្ត លោកអ្នក ឱ្យជួយថែរក្សាបរិស្ថាន ។ ដោយចាប់ផ្តើមពីក្នុងអំឡុង* **សប្តាហ៍ សុខដុមរមនា នៃអន្តរសាសនា**
*ពីថ្ងៃទី០១-ថ្ងៃទី០៧ ខែកុម្ភៈ ហើយបន្តពេញមួយជីវិត ។*

**ឌេនីស ខគឡេន** *( អ្នកសម្របសម្រួល)*
**( Denise Coghlan)**

ACT JUSTLY
LOVE TENDERLY
WALK HUMBLY



# សហប្រតិបត្តិការអន្តរសាសនាដើម្បី

# ការអភិវឌ្ឍប្រកបដោយនិរន្តរភាព

(អ៊ីន យូចេនសិន-ERNST JURGENSEN)

កាលពីឆ្នាំកន្លងទៅនេះ មានការប៉ុនប៉ងជាច្រើនត្រូវបានធ្វើឡើងដើម្បីជម្រុញឱ្យសាសនិកពីក្រុមសាសនាជាច្រើន ចូលរួមដោះស្រាយបញ្ហាសង្គមបច្ចុប្បន្ន។ នៅខែធ្នូ ឆ្នាំ២០១២ សិក្ខាសាលាមួយត្រូវបានធ្វើឡើងនៅមជ្ឈមណ្ឌលមេត្តា ករុណា ខេត្តសៀមរាប ដោយផ្តោតទៅលើប្រធានបទសំខាន់ចំនួនបួន៖ **បរិស្ថាន ពិការភាព និងការរំសាយសព្វាវុធបំលាស់ទីក្នុងតំបន់ដោយបង្ខំ និងការបណ្តេញចេញពីដីធ្លី**។សិក្ខាសាលាបន្ទាប់មួយទៀតត្រូវបានធ្វើឡើងក្នុងខែកក្កដា ឆ្នាំ ២០១៣ ស្តីពី **បញ្ហាដីធ្លី និងបរិស្ថាន** ។

នៅក្នុងសិក្ខាសាលាទាំងពីរនេះ បរិស័ទមកពី ឥស្លាម ពុទ្ធិសាសនា និងព្រះសហគមន៍គ្រីស្ទាន បានដាំដើមឈើទាំងអស់គ្នា។ **ដើមឈើ** ជានិមិត្តសញ្ញានៃរឿងរ៉ាវជាច្រើនដូចជាជីវិត គតិបណ្ឌិត ភាពរីកចម្រើន សម្រស់ ។ល។ នៅក្នុងវប្បធម៌ និងសាសនាជាច្រើន ដើមឈើមានអត្ថន័យពិសិដ្ឋ ហើយត្រូវបានដាំសម្រាប់លំអរ សាកលលោក ។

ក្រឡេកមើលទៅលើទិដ្ឋភាពដើមឈើកម្ពុជានាពេលបច្ចុប្បន្នវិញ ដើមឈើកំពុងក្លាយជាពូជរុក្ខជាតិមួយក្នុងសភាពគ្រោះថ្នាក់។ ក្នុងឆ្នាំ១៩៧៣ ដើមឈើគ្របដណ្តប់ផ្ទៃដី៧២.១១% នៃប្រទេសកម្ពុជា ប៉ុន្តែឥឡូវ ក្នុងឆ្នាំ២០១៣ ភាគរយគឺនៅតែ ៤៦.៣៣% ប៉ុណ្ណោះ ។

គម្របព្រៃឈើដីសែនក្រាស់បានធ្លាក់ចុះពី ៤១.៨៨% មក ១០.៨៣% នៅក្នុងកំឡុងពេលនេះ។ ជាមួយនឹងល្បឿនបំផ្លេចបំផ្លាញបច្ចុប្បន្ន ព្រៃដ៏ក្រាស់នេះ នឹងរលាយបាត់បង់តែពីរបីឆ្នាំទៀតប៉ុណ្ណោះ ដោយបង្កនូវផលប៉ះពាល់អាក្រក់ដល់ បរិស្ថាន អាកាសធាតុ និងជីវិតរស់នៅរបស់មនុស្សជាច្រើនពាន់នាក់។

ការដាំដើមឈើដោយសាសនិកពោពេញដោយក្ដីជំនឿ គឺធ្វើឡើងដោយក្ដីគោរព និងកិត្តយសនៃពិភពលោក ប៉ុន្តែក្នុងពេលជាមួយគ្នានេះ ក៏ជានិមិត្តសញ្ញានៃការតស៊ូមតិ និងការប្រឆាំងនឹងការកាប់ព្រៃឈើបច្ចុប្បន្ននៅក្នុងកម្ពុជា ។ ការដាំដើមឈើ គឺជាក្ដីបំណងតូចមួយ ដែលធ្វើឡើងដើម្បីប្រឆាំងនឹងការបាត់បង់ដើមឈើកម្ពុជារាប់លានដើម ។ ទន្ទឹមជាមួយនេះ គ្រាប់ពូជនៃក្ដីសង្ឃឹមត្រូវបានបណ្ដុះឡើង ក្ដីសង្ឃឹមដែលថា ការកាប់បំផ្លាញព្រៃឈើនឹងត្រូវបញ្ឈប់ ហើយកម្ពុជានឹងចូលទៅក្នុងផ្លូវនិរន្តរភាពនៃការអភិវឌ្ឍ មិនមែនជាការអភិវឌ្ឍរយៈពេលខ្លីដែលជាប្រយោជន៍មនុស្សមួយចំនួនតូច ហើយបង្កការគំរាមកំហែងដល់មនុស្សជាច្រើន។


រូបថតជុំគ្នា-សិក្ខាសាលាអន្តរសាសនា ២០១៣
មណ្ឌលមេត្តា ករុណា/JRS

ការដាំដើមឈើបានក្លាយជាសកម្មភាពស្នូលនៃព្រឹត្តិការណ៍របស់ក្រុមអន្តរសាសនាជាច្រើន។ ដើម្បីអបអរសាទរដល់ **សប្ដាហ៍សុខដុមរមនាអន្តរសាសនា ឆ្នាំ២០១៣** អ្នកកាន់សាសនាជាច្រើន មកពីគ្រប់តំបន់នៃប្រទេសកម្ពុជា បានដាំដើម ឈើជាច្រើនដើម ជាឧទាហរណ៍ ការដាំដើមឈើ នៅជើងឯក (វាលពិឃាត)។ ការដាំដើមឈើគឺជាផ្នែកមួយយ៉ាងសំខាន់នៅក្នុង **សប្ដាហ៍សុខដុមរមនាអន្តរសាសនាសកល ឆ្នាំ២០១៤** ដែលបាន ចាប់ផ្ដើមឡើងនៅសប្ដាហ៍ទីមួយនៃខែកុម្ភៈ។ តាមការប្រតិបត្តិ និងជានិមិត្តសញ្ញាការដាំដើមឈើអាចនាំសាសនិកដែលមានសាសនាផ្សេងៗគ្នា មករួមជាមួយគ្នាដើម្បីគោលបំណងរួមមួយ ជាឧទាហរណ៍ ការអភិវឌ្ឍដែលមាននិរន្តរភាព។ ប្រជាជនកម្ពុជា ទោះកាន់សាសនាអ្វីក៏ដោយ រងនូវផលប៉ះពាល់នៃការកាប់បំផ្លាញព្រៃឈើទាំងអស់គ្នា ដូច្នេះនេះជាតម្រូវការមួយក្នុងការចាប់ផ្ដើមការសហការណ៍ឆ្លងសាសនា គ្រប់សហគមន៍ រវាងស្ថាប័នសាសនា និងអ្នកដឹកនាំជាន់ខ្ពស់។ ការជំរុញទឹកចិត្ត និងកិច្ចសហការណ៍ពីគ្រប់កម្រិតសហគមន៍សាសនាគឺជាស្នូលសំខាន់ក្នុងការលើកកម្ពស់ផ្លូវថ្មីនៃការអភិវឌ្ឍប្រកដោយនិរន្តភាព ។ មានតែការចាប់ដៃធ្វើការជាមួយគ្នា ដើម្បីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពប៉ុណ្ណោះ ទើបព្រៃឈើកម្ពុជាអាចសង្គ្រោះបាន មុនពេលស្ដារលែងបាន។

# ប្លាស្ទិចអាចសម្លាប់បរិស្ថានរបស់យើង

(អ៊ុក ភិរម្យ -OUK PHIRUM និង តូរី ឌូស-TORI DUOOS)

អ៊ុក ភិរម្យ ធ្វើការនៅមន្ទីរកសិកម្ម ជាមួយគម្រោងមួយហៅថា **ភូមិមានសុខភាពល្អ ការរស់នៅប្រកបដោយសុខភាពល្អ**។ នៅពេលគាត់ទំនេរ គាត់ធ្វើការស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលសម្របសម្រួលយុវជនឥស្លាមកម្ពុជា។ ភិរម្យបានដឹងថាប្លាស្ទិចគឺជាបញ្ហានាំមុខមួយ ក្នុងការថែរក្សាបរិស្ថាននៃប្រទេសកម្ពុជា ។ គាត់ និយាយថា "ប្លាស្ទិចមានគុណវិបត្តិជាច្រើនដែលយើងមិនបានយល់ ហើយ អ្នកភូមិជាច្រើនបោះវាចោលពេញដី"។

ដើម្បីប្រយុទ្ធប្រឆាំងនឹងការពង្រាយសម្រាមរាយប៉ាយ និងការគំរាមកំហែងដល់បរិស្ថាន ភិរម្យបានដាក់ទំនួលខុសត្រូវលើខ្លួនគាត់ក្នុងការបង្រៀនប្រជាជន និងអប់រំអ្នកភូមិអំពីគ្រោះថ្នាក់នៃកាកសំណល់ ។ ជាពិសេស គាត់ បានអប់រំ អំពីប្លាស្ទិច និងការចោលសំរាមផ្តេសផ្តាស់។ អ្នកភូមិបោះប្លាស្ទិចពេញដី ហើយវា អាចជាការគំរាមកំហែងដល់បរិស្ថាន បើសិនជាមិនបានកំទេចវាចោល ។



ភិរម្យ បានសម្គាល់ឃើញពីឥទ្ធិពលវិជ្ជមាននៃគម្រោងភូមិមានសុខភាពល្អ ការរស់នៅមានសុខភាពល្អ នៅពេលសមាជិកពីភូមិដែលបានចូលរួម បានចាប់ផ្តើម រើសសំរាមដែលអ្នកភូមិបានបោះចោលបន្ទាប់ពីការប្រជុំ ។ "អ្នកភូមិ កំពុងចាប់ផ្តើមទទួលខុសត្រូវលើបរិស្ថានរបស់ពួកគាត់" ។

លក្ខណៈល្អមួយនៅក្នុងជីវិតរបស់ ភិរម្យ គឺគាត់ជឿលើសាសនាឥស្លាម។ គាត់ បានចែករំលែកថា សាសនាឥស្លាម មានក្តីគោរពស្រឡាញ់ធំធេងលើបរិស្ថាន។ គាត់បានចងចាំថា គម្ពីរកូរ៉ាន បានចែងយ៉ាងច្បាស់ថា មិនត្រូវកាប់សម្លាប់ធម្មជាតិ ដែលអ្នកមិនប្រើប្រាស់សម្រាប់ការរស់នៅនោះឡើយ។

ទោះបីជាការបោះចោលប្លាស្ទិចបានត្រឹមត្រូវ ហាក់ដូចជាការងារតូចមួយ ភិរម្យ គិតថាវាជាកិច្ចការសំខាន់ក្នុងការរក្សាឱ្យបានបរិស្ថានមានសុខភាពល្អ។ គាត់បញ្ចេញយោបល់ថា "បរិស្ថាននៅក្នុងប្រទេសកម្ពុជាផ្លាស់ប្តូរច្រើនណាស់" "ពីមុនយើងមានរដូវប្រាំង និងរដូវវស្សារច្បាស់លាស់ ប៉ុន្តែឥឡូវរដូវកាលបែរជាមិនមានភាពច្បាស់លាស់។ នេះមិនមែនជាការល្អសម្រាប់កសិករ និងស្រែចំការនោះទេ។ វាក៏ពិបាកក្នុងការចិញ្ចឹមសត្វ ពីព្រោះអាកាសធាតុក្តៅខ្លាំងណាស់។"

គម្រោងបរិស្ថាននៅក្នុងប្រទេសកម្ពុជារបស់ អង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍ (UNDP) បានបញ្ជាក់ពីក្តីបារម្ភនៃការផ្លាស់ប្តូរនៃអាកាសធាតុ និងបរិស្ថាននៅក្នុងប្រទេសកម្ពុជា ។ ភ្លៀងធ្លាក់កាន់តែខ្លាំងនៅរដូវវស្សារអាចនាំទៅរកកំណើនទឹកជំនន់ ការបាត់បង់ជីវៈចម្រុះ ការផ្លាស់ប្តូរកម្រិតទឹកសមុទ្រ និងការបង្កើនឧប្បទ្វិហេតុ ម៉ូសចម្លងជម្ងឺដូចជា គ្រុនចាញ់ និងគ្រុនឈាមជាដើម។

<u>**បញ្ហាប្រឈមៈ**</u>

- ព្យាយាមមិនប្រើថង់ប្លាស្ទិច បើមានថងប្លាស្ទិច ប្រើវាឡើងវិញ ។
- កុំបោះប្លាស្ទិចនៅលើដី ប៉ុន្តែកំទេចវាចោលដោយប្រុងប្រយ័ត្ន ។
- តើធ្វើដូចម្តេចទើបខ្ញុំ អាចរក្សាភូមិខ្ញុំឱ្យមានសោភ័ណ្ឌភាព?

# ការពារប្រទេសកម្ពុជា ពីបម្រែបម្រួលអាកាសធាតុ

ស្រីសុខមកពីភូមិដ៏តូចមួយពីខេត្តស្ទឹងត្រែង។នាងមកពីសហគមន៍ដែលមានព្រៃឈើដ៏ស្រស់ស្អាត ខៀវស្រងាត់ ដែលផ្តល់សព្វសារពើ ដែលជាការ ចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃរបស់អ្នកភូមិ ដូចជាអាហារ និងធនធានសម្រាប់ជាជម្រក។ ស្រី សុខ កើតនៅឆ្នាំ ១៩៥៤ ហើយប្តីរបស់គាត់បានបាត់បង់ជីវិតនៅសម័យប៉ុល ពត។

ខណៈដែលស្នាមជ្រួញលើមុខកាន់តែជ្រៅ ហើយភ្នែកកាន់តែមើលឃើញច្បាស់ សុខ បានផ្តើមនិទានពីកិច្ចខិតខំប្រឹងប្រែងរបស់គាត់ ក្នុងការការពារបរិស្ថាន។ សុខ បានក្លាយជាសកម្មជនក្នុងមូលដ្ឋាន ប្រឆាំងនឹងពួកអ្នកកាប់បំផ្លាញព្រៃឈើ ដោយជឿថា "បរិស្ថានអាចការពារមនុស្ស និងផ្តល់ជីវិតដល់ប្រជាជនកម្ពុជា" គាត់បានពន្យល់ ។ សុខ បានប្រាប់ទៀតថា ភូមិរបស់គាត់ជួបប្រទះការបំផ្លាញ ព្រៃដោយក្រុមហ៊ុនធំៗជាច្រើន ។ គាត់ បានសម្រេចចិត្ត ចាត់វិធានការ ក្នុងឆ្នាំ ២០០២ ជាមួយនឹងភាពសកម្មនិយមរបស់គាត់ ។ ជារឿយៗ សុខ តែងមានអារម្មណ៍ថា គាត់កំពុងធ្វើសង្គ្រាមជាមួយយក្ស "រូបកាយខ្ញុំ មិនមាំ តែខ្ញុំមានគំនិតហ្នឹងម្នាក់" គាត់បានបញ្ជាក់ ។



ព្រឹត្តិការណ៍ជាក់លាក់មួយ ដែលលេចធ្លោក្នុងការចងចាំរបស់គាត់ គឺក្នុងឆ្នាំ ២០១០ នៅពេលដែលអ្នកកាប់ព្រៃឈើ កាប់ឈើជាច្រើនដើម ។ នៅពេលដែលគាត់បានជួបអ្នកកាប់ឈើទាំងនោះ គាត់បានទៅជួបអាជ្ញាធរដើម្បីឱ្យពួកគាត់ ឃើញផ្ទាល់នឹងភ្នែក ហើយនិងកត់ត្រាពីព្រឹត្តិការណ៍នោះ។ ពួកអ្នកកាប់ឈើ បានគម្រាមជីវិតរបស់គាត់ បើសិនជាគាត់រាយការណ៍ដល់អាជ្ញធរ ប៉ុន្តែគាត់ គ្មានខ្លាចអ្វីនោះទេឡើយ។ គាត់បានប្រាប់ទៀតថាបន្ទាប់ពីរាយការណ៍ មន្ត្រីសាលាខេត្តបានចាត់វិធានការជាមួយអ្នកកាប់ឈើទាំងនោះ ហើយបានការពារគ្រួសាររបស់គាត់។ ជាអកុសល ក្រុមហ៊ុនកាប់ឈើឯកជនទាំងនោះ ជារឿយៗមានកម្លាំងសន្តិសុខរបស់គេ ដែលមិនអើពើនឹងសកម្មជននោះឡើយ។ ទំនាក់ទំនងរបស់ សុខ ជាមួយមន្ត្រីក្នុងភូមិ គឺវិជ្ជមាន ហើយពួកគាត់ បានជំរុញលើកទឹកចិត្តគាត់ឱ្យបន្តការការពារបរិស្ថាន។

ក្រៅពីការកាប់ឈើខុសច្បាប់ សុខ បានសម្គាល់ឃើញពីការផ្លាស់ប្តូរនៅក្នុងរដូវកាល ដែលគាត់ជឿថាជាលទ្ធផលនៃការធ្វើទុក្ខរុករានទៅលើបរិស្ថាន។ ប៉ុន្មានឆ្នាំកន្លងមក គាត់បានសម្គាល់ឃើញថាតំណក់ទឹកភ្លៀងមានការផ្លាស់ប្តូរនៅខេត្តស្ទឹងត្រែង ហើយអាកាសធាតុ ក៏ពិបាកព្យាករ ហើយការនេះបង្កភាពលំបាកដល់អ្នកភូមិ។

ស្រី សុខ បានសុំឱ្យរដ្ឋាភិបាលកំណត់ និងតាមដានការកាប់បំផ្លាញព្រៃឈើ។ គាត់ជឿថា ជារឿយៗ ក្រុមហ៊ុនជាច្រើននោះកំពុងកាប់ឈើលើសពីកម្រិតដែលរដ្ឋាភិបាលបានអនុញ្ញាត។ សូមគិតពីអ្នកភូមិ មុននឹងផ្តល់ការអនុញ្ញាតលើការកាប់ព្រៃឈើ ។

**បញ្ហាប្រឈម៖**

- តើសត្វព្រៃ និងធម្មជាតិបង្កផលប៉ះពាល់ដល់សហគមន៍របស់អ្នកយ៉ាងដូចម្តេច?
- ដាំដើមឈើក្បែរផ្ទះរបស់អ្នកនៅ **សប្តាហ៍សុខដុមរមនាអន្តរសាសនា**ដែលចាប់ផ្តើមនៅសប្តាហ៍ទីមួយក្នុងខែកុម្ភៈ ។

# ព្រៃឈើកម្ពុជា ផ្តល់អោយជីវិតដល់ប្រជាជនកម្ពុជា

**សកម្មជនសហគមន៍** ដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារបរិស្ថាននៅតំបន់មូលដ្ឋាន។ ពៅ ចិន្តា ជាសកម្មជនមកពីភូមិព្រៃឡង់ ក្នុងខេត្តព្រះវិហារ។ ព្រះវិហារគឺជាខេត្តមួយល្បីល្បាញពីប្រាសាទដ៏ស្រស់ស្អាត នៅជិតព្រំដែនខ្មែរ និងថៃ។ មូលហេតុមួយដែលខេត្តព្រះវិហាររក្សាបានព្រៃឈើស្រស់ស្អាតគឺដោយសារតែតំបន់នោះគ្របដណ្តប់ទៅដោយគ្រាប់មីនដ៏ក្រាស់ក្រែល ។

ជាអកុសល បរិស្ថាននៅតែរងហានិរភ័យនៃការអភិវឌ្ឍ ។ ពៅ ចិន្តា និយាយថា "បើសិនយើងបាត់បង់ព្រៃឡង់ ឬព្រៃឈើនោះ យើងនឹងបាត់បង់អាហារ និង ជីវភាពប្រចាំថ្ងៃ ហើយវានឹងបង្កផលវិបាកសម្រាប់យើងក្នុងការចិញ្ចឹមជីវិត" នាងបានពិពណ៌នាបន្ថែម ។ ទាំងនេះគឺជាកត្តាលើកទឹកចិត្តនៅពីក្រោយសកម្មភាពរបស់នាង។ ព្រៃឈើផ្តល់ផ្លែឈើព្រៃ និងបន្លែដែលអ្នកភូមិប្រើប្រាស់ប្រចាំថ្ងៃ ហើយក៏ផ្តល់អុសដុត និងឱសថបូរាណខ្មែរដែលនៅតែប្រើប្រាស់ជាទូទៅ ។ ចិន្តា បានរំលឹកពីកាល នាងធំឡើងនៅព្រៃឡង់ដែលឪពុករបស់នាងរកអាហារមកចិញ្ចឹមគ្រួសារពីការនេសាទ ។ ទោះជាយ៉ាងនេះក្តី នាងនិយាយទាំងទឹកមុខក្រៀមក្រំថា "ឥឡូវគ្មានត្រីចាប់ទៀតទេ ហើយធនធានធម្មជាតិរបស់យើ ងក៏ចេះតែបាត់បង់ទៅៗ" ។



ពីរបីឆ្នាំកន្លងទៅនេះព្រៃឡង់ បានជួបនឹងការកាប់បំផ្លាញ នៅពេលដែលក្រុមហ៊ុនបណ្តាក់ទុនលើដី ហើយកាប់ព្រៃឈើ ។ នោះហើយជាពេលដែលចិន្តា ចាប់ផ្តើមសកម្មភាពក្នុងបំណងការពារការបាត់បង់ព្រៃឈើ។ សំណាងល្អ នាងមានកម្លាំងជួយពីខេត្តជិតខាងចំនួនបួន ដែលជួបប្រទះបញ្ហាស្រដៀងគ្នាពីការកាប់បំផ្លាញព្រៃឈើ និងដែលបានរៀបចំក្នុងឆ្នាំ ២០០២។ នៅពេលសហគមន៍មួយត្រូវការសកម្មជនដ៏ខ្លាំងក្លា និងឱ្យបានចំនួនកាន់តែច្រើននោះបណ្តាញ នឹងសហការណ៍ដើម្បីជួយគ្នាទៅវិញទៅមក ។ ក្រុមនេះក៏បានជួបជុំគ្នាដើម្បីសរសេរលិខិតទៅរដ្ឋាភិបាលផងដែរ។

ទោះជាយ៉ាងនេះក្តី កិច្ចខិតខំប្រឹងប្រែងរបស់ចិន្តា មិនតែងទទួលបានការគាំទ្រនោះទេ។ នាង ជួបប្រទះបញ្ហាជាច្រើននៅពេលធ្វើការតស៊ូមតិ។ ចិន្តា បានប្រាប់ថា ជីវិតរបស់នាងក៏រងនូវការគំរាមកំហែងពីមុនមកដែរ ។ ប៉ុន្តែការគំរាមកំហែងនេះ មិនបានបញ្ឈប់នាងនោះទេ ដោយនឹងធានាអះអាងថានាងធ្វើសកម្មភាព"**ដើម្បីសហគមន៍និងក្មេងជំនាន់ក្រោយ**"។កាលពីមុននាងក៏ធ្លាប់រងការគំរាមកំហែងពីកម្លាំងនគរបាល ប៉ុនប៉ងចាប់រូបនាងផងដែរ។

ប្រភពអន្តរជាតិបានព្យាករថា បើសិនជាការកាប់បំផ្លាញព្រៃឈើនៅតែ បន្តទៅទៀតក្នុងល្បឿនដូចបច្ចុប្បន្ននេះ ពីរទៅប្រាំឆ្នាំទៀតព្រៃឡង់ នឹងរលាយសាបសូន្យ ។ ព្រៃឡង់បកប្រែពីភាសាក្នុងតំបន់មានន័យថា "ព្រៃយើង"។ នៅឆ្នាំ២០១១ ការពង្រាងច្បាប់មួយត្រូវបានធ្វើឡើងដើម្បីការពារព្រៃមួយចំនួននៅព្រៃឡង់ ទោះជាយ៉ាងនេះក្តីច្បាប់នេះមិនទាន់បានអនុវត្តនៅឡើយទេ [១]។

ពីឆ្នាំ ២០០០ ទៅ ឆ្នាំ ២០១៣ ប្រទេសកម្ពុជាបាត់បង់ព្រៃឈើ ១២,៦០០គ.ម$^{២}$ ហើយស្រោចស្រង់បានតែ ១,១០០ គ.ម$^{២}$ - ខាតបង់អស់ ៧%។
មានតែប្រទេសម៉ាឡេស៊ី ប៉ារ៉ាកាយ ឥណ្ឌូនេស៊ី និងក្វាតាម៉ាឡា ប៉ុណ្ណោះដែលមានអត្រាកាប់បំផ្លាញព្រៃឈើខ្ពស់ជាងគេ ។ (ការសិក្សាពីការធ្វើផែនទីម៉ារីឡែន)

**បញ្ហាប្រឈមៈ**

តើយើង អាចការពារ និងដាំព្រៃឈើរបស់យើងឡើងវិញដោយរបៀបណា?

១-ប្រយុទ្ធប្រឆាំងដើម្បីសង្គ្រោះព្រៃឡង់កម្ពុជា Deutsche Welle.
http://www.dw.de/fighting-to-save-cambodias-prey-lang-forest/a-16681283

## សុភមង្គល និងបរិស្ថាន ( HAPPINESS and ENVIRONMENT)

(បប់ ម៉ាត-BOB MAAT)

**តើអ្នកអាចវាស់វែងសុភមង្គលនៃប្រទេសមួយយ៉ាងដូចម្តេច** ?
នេះជាទស្សនាទាន ដ៏គួរឱ្យចាប់អារម្មណ៍មួយដែលព្រះរាជាណាចក្រ ប៊ូតាន យកមកប្រើយ៉ាងជោគជ័យ ។ ជាមួយនឹង **អត្រាសុភមង្គលសរុបជាតិ** (GNH) ខ្ពស់ជាងគេ ប៊ូតាន អាចត្រូវបានគិតថាជាប្រទេសគំរូមួយសម្រាប់ប្រទេសដទៃទៀត។

ដូចដែលព្រះមហាក្សត្រប្រទេសប៊ូតាន់បានពិពណ៌នា "ខ្លឹមសារនៃទស្សនវិទ្យានៃអត្រាសុភមង្គលសរុបជាតិ គឺជាសន្តិភាព និងសុភមង្គលរបស់ប្រជាជនយើង និងសន្តិសុខ ហើយនិងអធិបតេយ្យភាពជាតិយើង" 1 អត្រាសុភមង្គលជាតិ (GNH) គឺជារង្វាស់ប្រវែងគុណភាពប្រទេសមួយ តាមវិធីសាស្ត្រសង្គមនិយម ។ ផ្ទុយពីការ វាស់វែងគុណភាពផលិតផល និងលុយក្នុងប្រទេស GNH ផ្តោតទៅលើគុណតម្លៃជីវិតសម្រាប់ប្រជាជន និងប្រទេសជាតិ ។




ក្រមច្បាប់មាត្រា ១៧២៩ របស់ប៊ូតានថែងថា "បើសិនរាជរដ្ឋាភិបាលមិនអាចបង្កើតសុភមង្គលសម្រាប់ប្រជាជនរបស់ខ្លួន នោះមិនចាំបាច់មានរាជរដ្ឋាភិបាលនោះទេ។" ធាតុទាំងប្រាំបួននៃ GNH គឺ៖ សុខមាលភាពផ្លូវចិត្ត សុខភាព ការអប់រំ វប្បធម៌ ការប្រើពេល អភិបាលកិច្ចល្អ ការទ្រទ្រង់សហគមន៍ បរិស្ថាន និង និយាម(ស្តង់ដា)ជីវភាពរស់នៅ ។

រដ្ឋធម្មនុញ៖ បានថែងថា "ពលរដ្ឋទាំងអស់ត្រូវចូលរួមចំណែកក្នុងការការពារបរិស្ថានធម្មជាតិ អភិរក្សភាពចម្រុះសម្បូរបែបរបស់ប៊ូតាន និងទប់ស្កាត់គ្រប់ទម្រង់នៃការបំផ្លាញប្រព័ន្ធអេកូឡូស៊ី" ។

ដូចគ្នានឹងប្រទេសកម្ពុជាផងដែរ ប៊ូតានគឺជាប្រទេសកំពុងអភិវឌ្ឍន៍។ ប៊ូតានផ្តោតលើបរិស្ថាន។ ប៊ូតាន់ ផ្តោតលើការអភិរក្សបរិស្ថាន។ កិច្ចចាប់ផ្តើម ក្នុងការអភិវឌ្ឍត្រូវបានវាយតម្លៃដោយផ្អែកតាមផលប៉ះពាល់បរិស្ថាន។ កត្តាមួយក្នុង ការផ្តោតទៅលើបរិស្ថានរបស់ប្រទេសនេះគឺឬសគុលដ៏រឹងមាំនៃពុទ្ធសាសនា ។ ពុទ្ធិសាសនា ផ្តោតទៅលើសារៈសំខាន់នៃបរិស្ថានក្នុងជីវិត របស់យើង។

វាប្រហែលជាពិបាកក្នុងការប្រៀបធៀបពី សមិទ្ធិផលនៃប្រទេសខុសគ្នា ប៉ុន្តែវា មិនមែនជារឿងចៃដន្យដូចគ្នាដែលថា ប៊ូតានមាន GNH ខ្ពស់ ហើយមានគម្របព្រៃឈើកើនច្រើនជាងគេនៅ ក្នុងពិភពលោកនោះទេ ។ កត្តាទាំងពីរត្រូវទៅស្របគ្នា។ ការប្តេជ្ញាចិត្ត របស់ប៊ូតាន ក្នុងការអភិរក្សបរិស្ថាន គឺជាឧទាហរណ៍មួយដែលបញ្ជាក់ថា ប្រទេសកំពុងអភិវឌ្ឍន៍មិនមែនមិនចាំបាច់គិតពីធម្មជាតិ ដើម្បីឱ្យមានវឌ្ឍនភាពក្នុងការអភិវឌ្ឍនោះទេ ។

**បញ្ហាប្រឈម៖**

គិតអំពីទំនាក់ទំនងរវាងបរិស្ថាន និងសុភមង្គលផ្ទាល់ខ្លួនរបស់អ្នក។ លើកទឹកចិត្តរដ្ឋាភិបាលរបស់អ្នក ឱ្យមើលឃើញពីគុណតម្លៃនៃការអភិវឌ្ឍ ក្នុងការអភិរក្សព្រៃឈើជាតិ និងលំនៅដ្ឋានធម្មជាតិ ។




បឹងឆ្មារ, ខេត្តកំពង់ធំ

## ត្រីគល់រាំង (CATLOCARPIO SIAMENSIS) នៅមានជីវិត!!!

(ហ្គាព្រីអែល ឡាមុក-Gabriel Lamug-Nañawa SJ)

នៅសប្តាហ៍ចុងក្រោយខែវិច្ឆិកា ឆ្នាំ ២០១៣ គ្នាយើងប្រាំពីរនាក់មកពីក្រុងភ្នំពេញ ខេត្តបាត់ដំបង និងកំពង់ធំ បានចូលរួមក្នុងដំណើរសិក្សាស្រាវជ្រាវដោយធ្វើដំណើរតាមទូកចេញពីខេត្តកំពង់ធំ តាមស្ទឹងសែនទៅកាន់ឆ្នុកទ្រូរួចកាត់បឹងទន្លេសាបទៅបឹងឆ្មារ។ គោលបំណងរបស់យើងគឺចូលទៅតំបន់សំខាន់ពីរ ក្នុងចំណោមតំបន់សំខាន់បី ដើម្បីទៅមើល ជីវៈចម្រុះនៅក្នុងបឹងទន្លេសាប និងមើលថា តើអាចជួយដាំដើមឈើដែលជាព្រៃលិចទឹកឡើងវិញបានដែរឬទេ ។

បឹងទន្លេសាប មានទីតាំងស្ថិតនៅចំកណ្តាលនៃទិដ្ឋភាពព្រៃឈើ នៃប្រទេសកម្ពុជា ។ វាជាបឹងទឹកសាប និងជាជម្រកព្រៃលិចទឹកដ៏ធំជាងគេនៅអាស៊ីអាគ្នេយ៍ ហើយវាជួយទ្រទ្រង់ជីវិតហ្វូងបក្សីទឹកធំជាងគេដែលរស់នៅក្នុងបឹងនេះ។ វាជាជម្រកដល់ត្រី ១៥០ ប្រភេទ និងជាជម្រកដល់ពពួកបាណកសត្វ សត្វល្មូន និងបក្សាបក្សីជាច្រើនទៀត។ ប្រជាជនប្រមាណ ៣ លាននាក់ ពឹងផ្អែកលើបឹងនេះ និងល្បាប់ភក់របស់វា ដើម្បីរកអាហារ និងជីវភាពរស់នៅ រួមមានការនេសាទ និងកសិកម្ម ។ ព្រោះបឹងនេះសម្បូរទៅដោយជីវៈចម្រុះ និងគុណតម្លៃសង្គមសេដ្ឋកិច្ចដល់មនុស្សជាច្រើន ទន្លេសាប និងដីល្បាប់របស់វា ដើរតួយ៉ាងសំខាន់នៅក្នុងជីវិតរស់នៅរបស់ប្រជាជនកម្ពុជា ។




លក្ខណៈពិសេសមួយនៃបឹងនេះ គឺរបបទឹកជំនន់ប្រចាំឆ្នាំរបស់វា។ នៅរដូវវស្សា ទឹកចេញពីបឹងទន្លេសាប ចូលទៅទន្លេមេគង្គតាមទន្លេសាប លើសកម្រិត ដូច្នេះ ហើយទិសដៅនៃការហូរនៅទន្លេសាប ក៏ច្រាសមកវិញ។ ចលនានេះ ផ្តើមឱ្យមានទឹកជំនន់ប្រចាំឆ្នាំនៃបឹងទន្លេសាប និងតំបន់លិចទឹកជុំវិញរបស់វា។ បន្ទាប់មក នៅពេលដែលកម្រិតទឹកទន្លេមេគង្គថយចុះនៅចុងរដូវវស្សា ក្នុងខែតុលា លំហូរទឹកក្នុងទន្លេសាបប្រវែង ១០០គ.ម ហូរច្រាសមកវិញម្តងទៀត ហើយបឹងទន្លេសាបស្រកចុះ ។

របបទឹកជំនន់របស់បឹង គឺជាកត្តាសំខាន់មួយក្នុងចំណោមកត្តាសំខាន់ផ្សេងទៀតដែលធ្វើឱ្យ ផលិតផលត្រីកកើត ដែលចិញ្ចឹមមនុស្សរាប់លាននាក់។ ប្រការនេះបន្ថែមដោយ តំបន់ជីវៈចម្រុះចំនួនបី នៅក្នុងប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាប (ឧទាហរណ៍ ព្រៃកទាល់ បឹងឆ្មារ និងចុងស្ទឹងសែន) ដែលជាជម្រកសំខាន់បំផុតសម្រាប់ផ្តល់អាហារដល់ត្រីធ្វើចំណាកពីកន្លែងផ្សេងចូលមក។ ក្នុងការធ្វើដំណើររបស់យើង យើងបានចូលទៅបឹងឆ្មារ និងព្រៃលិចទឹកស្ទឹងសែន ហើយបានជួបមន្ត្រីរដ្ឋាភិបាលដែលការពារតំបន់ទាំងនោះ។ ពួកគាត់ស្វាគមន៍និងលើកទឹកចិត្តលើគំនិតនៃការដាំព្រៃលិចទឹកជាមួយពួកគាត់

អ្វីដែលជារង្វាន់បន្ថែមនោះ យើងបានដឹងថា **ត្រីគល់រាំង** ដែលរងការគំរាមកំហែងនោះ មិនទាន់បាត់បង់នៅឡើយទេ។ បឹងទន្លេសាបគឺជាទីកន្លែងមួយដ៏សំខាន់ក្នុងចំណោមជម្រកដទៃទៀតដែលមានត្រីគល់រាំង ត្រីបេតិកភ័ណ្ឌជាតិរបស់ប្រទេសកម្ពុជា ដែលធំធាត់ដល់ ៣ម មានទម្ងន់ដល់ ៣០០គ.ក ។ ទោះជាយ៉ាងនេះក្តី ប៉ុន្មានឆ្នាំថ្មីៗនេះ គេមិនមានឃើញត្រីនេះនៅបឹងដ៏ធំនេះទេ ដែលនេះបង្កើតជាការភ័យខ្លាចថា ត្រីនិមិត្តរូបមួយនេះបានបាត់បង់ពីផ្ទៃទឹកកម្ពុជា។

ដូច្នេះហើយ យើងមានក្តីរីករាយដែលបានឮពីមន្ត្រីរដ្ឋាភិបាលនៅបឹងឆ្មារថា នៅខែមេសា ឆ្នាំ ២០១៣ នេះ អ្នកភូមិបានរាយការណ៍ពីការរកឃើញត្រីគល់រាំងមួយដែលគេជឿថាបានងាប់ដោយសារខ្យល់ព្យុះថ្មីៗនៅលើបឹង។



ត្រីគល់រាំង, ខែមេសា ឆ្នាំ២០១៣
(រូបថត ផ្តល់ដោយមន្ត្រីការពារនៅបឹងឆ្មារ)

ការរកឃើញនេះ ផ្តល់ក្តីសង្ឃឹម ថាមានត្រីគល់រាំងដទៃទៀតនៅបឹងឆ្មារ ហើយតំបន់ការពារស្នូលនេះ អាចជួយដល់ការរស់រានមានជីវិត និងការលូតលាស់នៃត្រីប្រភេទនេះ និងពូជត្រី និងជីវៈចម្រុះសំខាន់ផ្សេងទៀតនៅបឹងទន្លេសាប និងតំបន់លិចទឹករបស់វា។






ដើមឈើផ្តល់ជីវិត-ព្រះវិហារតូច នៅមណ្ឌលវិបស្សនាសៀមរាប/JRS

# បិទផ្ចិតចន្លោះ ៖ ជួយមាតាធម្មជាតិដោយធ្វើជីកំប៉ុស្ត

(ហ្គាព្រីអែល ឡាមុក-Gabriel Lamug-Nañawa SJ)

សប្តាហ៍មុន នៅពេលដែលខ្ញុំធ្វើបទបង្ហាញទៅកាន់អង្គការក្នុងស្រុកមួយ ខ្ញុំបានលើកឡើងថា ពិភពលោកសព្វថ្ងៃគ្មានទឹកថ្មីនោះទេ។ទឹកដែលមាននៅលើលោកនេះគឺកើតឡើងពីបរិមាណថេរ មិនកើន ហើយក៏មិនថយ ។ បច្ចុប្បន្ននេះ ទោះបីជា យើង ចង់បង្កើតទឹកថ្មី ទាំងធម្មជាតិ ទាំងមនុស្ស មិនអាចបង្កើតបាននោះទេ។

សិក្ខាកាមម្នាក់ពិតជាចង់ដឹងអំពីគំនិតនេះ ហើយបានសួរថា "បើសិនជាដូច្នោះមែនជាមួយមនុស្សច្រើនជំនាន់ដែលរស់ និងស្លាប់ អញ្ចឹងយើងមិនមែនជាអ្នកដែលផឹកទឹកស្អាតមុនគេនោះទេ។" វាអាចពិតដូច្នោះមែន។ វដ្តនៃទឹក ពីចំហាយទឹក ទៅជាកំណកអាកាស ទៅតំណក់ទឹកភ្លៀង និងច្រោះ និងជ្រាប មានន័យថាទឹកមិនដើរតាមផ្លូវត្រង់នោះទេ ប៉ុន្តែវាត្រូវបានវិលទៅវិលមកម្តងហើយម្តងទៀតជាច្រើនសហស្សវត្ស។ ទឹកដែលយើងផឹករាល់ថ្ងៃត្រូវបានផែនដីច្រោះយ៉ាងស្អាតហើយមកដល់យើងជាផលិផលលក្ខណៈកែច្នៃបែបធម្មជាតិ ។ ការកែច្នៃឡើងវិញ ជាវិធីសាស្ត្ររបស់ធម្មជាតិក្នុងការបង្កបង្កើតធនធានរបស់ខ្លួនឡើងវិញ។

ទោះជាយ៉ាងនេះក្តី មនុស្សយើងភាគច្រើនមិនគិតដូច្នេះទេ។ យើងយល់ទៅលើការប្រើប្រាស់របស់របរលក្ខណៈត្រង់៖ ប្រមូលវត្ថុធាតុដើម ចម្រាញ់ធ្វើផលិតផលទិញ និងលក់ផលិតផលនោះ ប្រើវាមួយរយៈ ដូរយករបស់ដដែលតែកំណែថ្មី បោះអាចាស់ចោល។ការធ្វើបែបនេះបង្កើតសំណល់ជាច្រើន ហើយមិនបានជួយធម្មជាតិឱ្យកែច្នៃធនធានរបស់វាដើម្បីនាំមកនូវអំណោយទានថ្មីនោះទេ ។



បិទផ្ចិតចន្លោះ ហើយជួយធម្មជាតិ ឱ្យកែច្នៃសំណល់របស់យើង

ក្នុងការផ្សំវត្ថុធាតុសរីរាង្គស្ងួត និងពណ៌ត្នោត (សម្បូរកាបូន) ជាមួយធាតុពណ៌បៃតង និងសំណើម (សម្បូរអាសូត) ជាមួយនឹងបរិមាណត្រឹមត្រូវនៃទឹក និងអុកស៊ីហ្សែន យើងអាចសហការណ៍ជាមួយធម្មជាតិ និងបាក់តេរីអាកាសជីវសាស្ត្រ ដែលធម្មជាតិប្រើដើម្បីផ្លាស់ប្រែសំណល់សរីរាង្គដែលបានបោះចោល ទៅជាគំនរដីពណ៌ត្នោត សម្បូរទៅដោយសារធាតុចិញ្ចឹម ។ ដំណើរការ វេទមន្តនេះត្រូវបានគេហៅថា **ធ្វើកំប៉ុស** ដែលជាវិធីសាស្ត្រមួយនៃការសហការជាមួយធម្មជាតិក្នុងដំណើរការកែច្នៃមុខមាត់ថ្មីរបស់ផែនដី។



បរិមាណសមស្របនៃកាបូន និងអាសូត លាយជាមួយទឹក និងអុកស៊ីហ្សែន កែច្នៃសំណល់ឱ្យទៅជាវត្ថុធាតុថ្មីដែលសម្បូរសារធាតុចិញ្ចឹម។



ផលិតផលកែច្នៃសម្រេច៖ គំនរដីដែលសម្បូរសារធាតុចិញ្ចឹម និងការត្រៀមខ្លួនជាស្រេចដើម្បីផលិតផ្លែឈើថ្មីដ៏ល្អ។

# សិក្ខាសាលា «អន្តរសាសនា»

ថ្ងៃទី១១-ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០១២
មណ្ឌលមេត្តា ករុណា ខេត្តសៀមរាប






**ចូរប្រព្រឹត្តតែអំពើយុត្តិធម៌
ស្រលាញ់ដោយករុណាធម៌ គោរពគ្នាទៅវិញទៅមក**

## គំនិតសំខាន់

ពុទ្ធបរិស័ទ គ្រីស្តបរិស័ទ និងឥស្លាមបរិស័ទ ត្រូវបានអញ្ជើញឱ្យមក ស្វែងយល់ទាំងអស់គ្នា ដើម្បីដឹងថាតើប្រពៃណីសាសនារបស់គេបាន ទូន្មានដូចម្តេចខ្លះក្នុងការធ្វើសកម្មភាពដើម្បីយុត្តិធម៌ ។ ទាំងអស់គ្នា ទាញយកប្រពៃណីខុសៗគ្នានេះ សហការណ៍ជាមួយគ្នាដើម្បីឆ្លុះបញ្ចាំង និងរៀបចំផែនការណ៍អហឹង្សាដើម្បីលើកឡើងមកដោះស្រាយនូវបញ្ហាប្រឈមបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា។



ចាត់តាំងពីសម័យកាលដ៏រន្ធត់នៃវាលពិឃាត កម្ពុជាបានបង្កើតនូវជំហានដ៏ល្អមួយចំនួនទៅកាន់សន្តិភាព ការផ្សះផ្សារនិងយុត្តិធម៌។ ទោះជាយ៉ាងនេះក្តី នេះគឺជាដំណើរវែងឆ្ងាយ ហើយមានការងារជាច្រើនទៀតត្រូវធ្វើ ដើម្បីឱ្យកម្ពុជាគឺជាផ្នែកមួយនៃពិភពលោកពោពេញទៅដោយ យុត្តិធម៌ សន្តិភាពដ៏ពិតប្រាកដដែលសាសនាទាំងចង់បាន ។

បញ្ហាដែលផ្តោតសំខាន់ទាំងបួនរួមមាន៖
**បរិស្ថាន បំលាស់ប្តូរលំនៅដោយបង្ខំ ការបណ្តេញចេញពីដីធ្លី និងពិការភាព ។**

## គោលបំណង

- ការស្តាប់ដំណើររឿងរបស់បងប្អូនដែលរងរបួសដោយសារសង្រ្គាម ប្តូរទីជម្រោកពីទឹកដី ឬពីមាតុប្រទេស ឬជួបប្រទះនឹងផលប៉ះពាល់នៃការបំផ្លាញបរិស្ថាន។
- ស្រូបយក ឧត្តមគតិពីជំនឿសាសនាផ្សេងៗរបស់ពុទ្ធសាសនា ឥស្លាម និងគ្រីស្ទាន ដើម្បីជម្រុញសកម្មភាពដើម្បីយុត្តិធម៌។
- ប្តេជ្ញារកវិធីសាស្រ្តដើម្បីធ្វើសកម្មភាពជាសមូហភាព និងបុគ្គលដើម្បីជួយឱ្យយុត្តិធម៌ និងសន្តិភាពដុះដាលកាន់តែជ្រៅនៅកម្ពុជា។



# ដំណើរការពិតប្រាកដនៃកម្មវិធី

“ចាំមពលនៃអ្នកដែលបានទទួលរងទុក្ខវេទនាដោយមិនបាត់បង់ក្ដីសង្ឃឹមៗ
ពួកគេគឺជាក្បាលម៉ាស៊ីននៃបំលាស់ប្ដូរសង្គម”

*-សម្រង់សម្ដីពីជញ្ជាំងចងចាំ*

សន្និបាទបានចាប់ផ្ដើមជាមួយនឹងសក្ខីភាពរបស់បុគ្គលដែលរងផលប៉ះពាល់ដូចដែលមាននៅក្នុងប្រធានបទនៃសន្និបា ។ ជនភៀសខ្លួន រ៉ូហ៊ីងយ៉ា បានប្រាប់ដំណើររឿង របស់គាត់ពីការនិរទេស និងភាពគ្មានសញ្ជាតិរបស់គាត់។ ស្ត្រីម្នាក់ ដោយការបណ្ដេញចេញឱ្យប្ដូរទីលំនៅដ្ឋាន បានប្រាប់ដំណើររឿងរបស់គាត់ពីការបណ្ដេញចេញជាច្រើនលើកច្រើនសារ។ ដោយក្ដីក្លាហានយុវជនម្នាក់ដែលដាច់ជើងទាំងពីរនិងដៃម្ខាងដោយសារគ្រាប់មីន បានចែករំលែក បទពិសោធន៍របស់គាត់ ។ ព្រះសង្ឃ ដែលរងផលប៉ះពាល់ពីការបាត់បង់ព្រៃឈើបានប្រាប់ពីដំណើររឿងរបស់លោក

សិក្ខាកាម ទាំងអស់គ្នា ឆ្លុះបញ្ចាំងពីដំណើររឿងជាច្រើន និងផ្ដល់ចម្លើយជាច្រើន។ មតិយោបល់ខ្លីៗត្រូវបានបិទនៅលើជញ្ជាំងចងចាំសម្រាប់ជាការជំរុញទឹកចិត្ត។ ធនធានស្ដីពីប្រធានបទនីមួយៗត្រូវបានផ្ដល់នៅក្នុងកញ្ចប់ស្វាគមន៍សម្រាប់សិក្ខាកាមម្នាក់ៗ ។

ចំណេះដឹងជំនាញនីមួយៗត្រូវបានចែកចាយលើប្រធានបទនីមួយៗ រួមទាំងទស្សនៈក្នុងតំបន់ និងទស្សនៈជាតិ។ លើកយកមកពិភាក្សាពីអ្វីដែលប្រជាជនកំពុងធ្វើដើម្បីធ្វើឱ្យប្រសើរឡើងដល់ស្ថានភាព និងជំនៈឧបស័គ្គ និង សំណួរសំខាន់ៗដែលនៅតែត្រូវការចម្លើយ។

បង្កើតជារង្វង់សិក្សានៅលើប្រធានបទនីមួយៗនៃប្រធានបទទាំងបួន ដើម្បីមានការសន្ទនាបន្ថែមជុំវិញប្រធានបទផ្ដល់ជូន។ នៅក្នុងក្រុមអន្តរសាសនាតូច អ្នកចូលរួមនឹងទទួលបានអត្ថប្រយោជន៍ពីការពិភាក្សាស៊ីជម្រៅ ចែកចាយបទពិសោធ និងទស្សនៈ និងសួរដេញដោលគ្នាទៅវិញទៅមក។ ក្រុមនីមួយៗ លើកឡើងនូវវិធីសាស្ត្រដើម្បីលើកកម្ពស់សកម្មភាព។

នៅចុងបញ្ចប់ បន្ទាប់ពីការពិភាក្សាពីបញ្ហាប្រឈមជាច្រើននៅកម្ពុជា ថ្ងៃបន្ទាប់មកទៀតបានចាប់ផ្ដើម ជាមួយការចែកចាយទស្សនៈពីក្រុមសាសនានីមួយៗ ។ សម្រង់សម្ដីលើកទឹកចិត្តពីវប្បធម៌ប្រពៃណីនីមួយៗត្រូវបានបញ្ចូលទៅក្នុងកូនសៀវភៅតូច “ពាក្យពេជន៍នៃជំនឿ” បន្ថែមលើនេះ វាគ្មិនដែលទទួលបានការបង្រៀនស៊ីជម្រៅពីគ្រីស្ដសាសនា ពុទ្ធសាសនា និងឥស្លាមជម្រុញយកបញ្ហារបស់ក្រុមលុបបំបាត់គ្រាប់មីនពីដួងចិត្ត និងការដើរធម្មយាត្រាដើម្បីយុត្តិធម៌។



# បញ្ហាចំនួន៨ ដែលយើងផ្តោត

"ធម្មជាតិតែងតែផ្តល់ជីវិតដល់អ្នក តើអ្នកគួរតែផ្តល់ជីវិតដល់ធម្មជាតិវិញដែរឬទេ? តើអ្នកបានធ្វើកិច្ចការប៉ុណ្ណាហើយដើម្បីថែរក្សាធម្មជាតិ?"

1

**ការផ្លាស់ទីលំនៅដោយបង្ខំ៖** រ៉ូហ៊ីងយ៉ា គឺជាជនជាតិភាគតិចឥស្លាមនៅប្រទេសភូមាដែលត្រូវ បានគេដកសញ្ជាតិ។ ថ្មីៗនេះពួកគេក្លាយជាជនគ្មានសញ្ជាតិ និងត្រូវបានគេចាត់ទុកថាជាជនជាតិភាគតិចដែលរងការធ្វើទុកបុកម្នេញច្រើនជាងគេ។ ពួកគេត្រូវបានបង្ខំឱ្យរត់ចោលប្រទេសស្វែង រកការការពារ។

ការពិភាក្សាជាក្រុម៖ សារៈសំខាន់នៃការយល់ដឹងពីឬសគល់នៃជម្លោះ- តើវាជាបញ្ហាដែនដី បុព្វបុរស សាសនាមែនទេ? ហេតុអ្វីអ្នកដឹកនាំសហគមន៍មិនចាត់វិធានការដោះស្រាយ? សាលាសន្តិភាពត្រូវបានប្រើប្រាស់ដើម្បីជា ឧទាហរណ៍ ដើម្បីពិភាក្សា មេរៀចំនួនបីនៃការដោះស្រាយជម្លោះ ៖ អត្តសញ្ញាណ ឬសគល់នៃជម្លោះ និងការប្លែងទំនាស់ ។

2

**ការបណ្តេញចេញពីដី៖** កម្ពុជាកំពងប្រឹងប្រែងដោះស្រាយការយកដីធ្លី និងការបង្ខំបណ្តេញចេញពីដីធ្លី។ គ្រួសារជាច្រើនបានផ្លាស់ប្តូរទីលំនៅ បាត់បង់ដីធ្លី ផ្ទះសម្បែង ការងារ និងរបរចិញ្ចឹមជីវិត។ ក្រោយពីសង្គ្រាម គ្រួសារជាច្រើនគ្មានប័ណ្ណកម្មសិទ្ធិដីធ្លី ដូច្នេះគ្មានសុវត្ថិភាពដីធ្លីនោះទេ។

ការពិភាក្សាជាក្រុម៖ សហគមន៍ត្រូវមានយុទ្ធសាស្ត្រ និងរួបរួមគ្នា និងលើកកម្ពស់ការយល់ដឹងក្នុងចំណោមប្រជាជនកម្ពុជា។ ប្រជាជនដែលកាន់សាសនាផ្សេងគ្នាអាចជាកម្លាំងគាំទ្រការផ្លាស់ប្តូរ ដែលរួមមានកិច្ចផ្តួចផ្តើមធ្វើប័ណ្ណកម្មសិទ្ធិដីធ្លី។

3

**បរិស្ថាន៖**គេបាននឹកចាំថានៅជំនាន់ខ្មែរក្រហម នៅពេលដែលប្រជាជនរងការឈឺចាប់ និងទុក្ខសោក ធម្មជាតិក៏បង្ហាញសញ្ញានៃក្តីទុក្ខសោកនោះដែរ។ មនុស្ស និងរុក្ខជាតិគឺមានទំនាក់ទំនងគ្នាទៅវិញទៅមក។ ការបំផ្លាញបរិស្ថាន គឺការបំផ្លាញគ្រូខ្លួនឯង និងជីវិត ខាងព្រលឹងវិញ្ញាណ។

**ការពិភាក្សាជាក្រុម៖** កសាងគំរូល្អៗ សម្រាប់ក្មេងៗ និងមនុស្សជំនាន់ក្រោយ។ ធ្វើការជាមួយគ្នាដើម្បីទប់ស្កាត់ទង្វើបំផ្លិចបំផ្លាញបរិស្ថាន ។ ដាំដើមឈើ!!!

4

**ពិការភាព៖** មនុស្សជាច្រើននៅក្នុងប្រទេសកម្ពុជា ពុះពារនឹងពិការភាព ដោយសង្គ្រាម និងជម្ងឺ។ ជនពិការ និងជនរងគ្រោះពីគ្រាប់មីនទាន់ផ្ទុះ បានធ្វើការជាមួយគ្នា ដើម្បីលុបបំបាត់គ្រាប់មីនកប់ក្នុងដីនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់សិទ្ធិជនពិការ។

ការពិភាក្សាក្រុម៖ ពិចារណាទៅលើឋានៈជនជាតិភាគតិចជាទម្រង់មួយនៃពិការភាព។ សារៈសំខាន់នៃការយកខ្លួនចូលក្នុងស្ថានភាពអ្នកដទៃដើម្បីយល់ដឹងពីបទពិសោធន៍ខុសៗគ្នា។

**លុបបំបាត់គ្រាប់មីនក្នុងចិត្ត។**

# តើប្រពៃណី សាសនា
# របស់យើងថាយ៉ាងដូចម្ដេច?

យុត្តិធម៌នៅក្នុងសាសនាឥស្លាមមានន័យថា
សេចក្ដីស្រឡាញ់ទៅកាន់អ្នកដទៃ ការសងសឹកមិនមែន
ជាជម្រើស ប៉ុន្តែត្រូវអត់ធ្មត់
ការកាន់តាមសិលទាំងប្រាំរបស់ពុទ្ធសាសនា៖
មិនត្រូវបង្កគ្រោះថ្នាក់ដល់គេ មិនត្រូវលួច
ជៀសវាងពីតណ្ហាមិនសមរម្យ មិនត្រូវកុហក និង
មិនត្រូវធ្លាក់ចូលទៅក្នុងការស្រវឹងពាលា
នៅក្នុងជំនឿគ្រីស្ទាន ការអត់ទោសជាការអនុគ្រោះដែល
ឱ្យភាគីមានជម្លោះផ្លាស់ប្តូរ ក្លាយជាអ្នកមានក្ដីមេត្តា
និងប្រកបដោយក្ដីស្រឡាញ់។
ការអាណិតអាសូរ មេត្តាករុណា គឺជាគន្លឹះនៃ
ជំនឿសាសនាទាំងអស់នៅក្នុងប្រទេសកម្ពុជា។



## សិក្ខាកាមប្តេជ្ញាថា៖

1. ផ្សព្វផ្សាយ និងរក្សាគាំពារសិទ្ធិជនពិការគ្រប់ទិសទី ។
2. បង្កើនការយល់ដឹងពីស្ថានភាពប្រជាជនរ៉ូហ៊ីងយ៉ា និងអញ្ជើញអ្នកមានចំណេះដឹងមករៀបចំផែនការយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព
3. ជំរុញកិច្ចប្រឹងប្រែងដើម្បី យុត្តិធម៌ ការផ្តល់កម្មសិទ្ធិដីធ្លី និងសន្តិភាព សហការប្រឆាំង នឹងអំពើអយុត្តិធម៌ និងជម្លោះដីធ្លី
4. ជំរុញកិច្ចការពារបរិស្ថាន ទឹកស្អាត ការដាំដើមឈើ និងសោភ័ណភាព

អនុវត្តតាមការប្រារពពិធីដាំដើម
ឈើអន្តរសាសនា ។ សិក្ខាកាម
បានឯកភាពជួបជុំក្រុមអន្តរសាសនា
ក្នុងសប្តាហ៍សុខដុមរមនាអន្តរសាសនា

## លទ្ធផល:

**ស្ដាប់** ដំណើររឿងអ្នកដែលជួបនឹងការឈឺចាប់។
**មើលឃើញ** ការឈឺចាប់នេះនាំមកនូវទឹកភ្នែក និងក្ដីអស់សង្ឃឹម ដែលផ្លាស់ប្តូរទៅជាការតស៊ូ ការអាណិតអាសូរ និងក្លាហានចេញជាសកម្មភាពដើម្បីយុត្តិធម៌។
**មានអារម្មណ៍** ថាក្នុងដួងចិត្ត ចិត្តមេត្តា ករុណា ការឈឺចាប់គឺមាននៅក្នុងយើង។
**រៀនសូត្រ** ពីបញ្ហាប្រឈមនៃការបណ្ដេញចេញពីដីធ្លី ពិការភាព ការបង្ខំឱ្យផ្លាស់ប្តូរទីលំនៅ និងបរិស្ថាន និងថាតើទាំងអស់នេះមានទំនាក់ទំនងគ្នាទៅវិញទៅមកយ៉ាងដូចម្ដេចខ្លះ។
**ឆ្លុះបញ្ចាំង** លើជំនឿសាសនារបស់យើង និងទស្សនៈរបស់ពួកគេ ដែលជំរុញយើងឱ្យធ្វើសកម្មភាពដើម្បីយុត្តិធម៌។
**បង្ហាញ** ពីការយល់ដឹងជាថ្មីពី ក្ដីមេត្តា ករុណា គតិបណ្ឌិត យុត្តិធម៌ ភាពថ្លៃថ្នូររបស់គ្នាទៅវិញទៅមក ការអត់ទោស ការផ្សះផ្សា សេចក្ដីស្រឡាញ់ និងបដិសេធន៍សេចក្ដីសម្អប់ និងការសងសឹក ។ បំបាត់សង្គ្រាមសាសនាក្នុងចិត្ត ។

នៅក្នុង **សប្តាហ៍សុខដុមរមនា នៃអន្តរសាសនា** សាសនាទាំងអស់ទូទាំងពិភពលោក នឹងសហការគ្នា ដើម្បីធ្វើឱ្យពិភពលោកយើងនេះក្លាយជាទីកន្លែងដែលប្រសើរជាងមុន ។

តើអ្នកមានគំនិតយោបល់យ៉ាងណាខ្លះ ចំពោះបរិស្ថាន និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅប្រទេសកម្ពុជា ?

តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីឱ្យមានភាពប្រសើរជាងមុន?

គ្មាននរណាម្នាក់ពូកែធ្វើកិច្ចការអ្វីមួយ ដែលគាត់មិនស្រលាញ់នោះទេ **(NFS GRUNDTVIG (1783-1872)**


**បោះពុម្ពដោយ:** DANMISSION JRS accompany • serve • advocate

**អ្នកផលិត**: សាក់ សុភ័ក្រ្ត តូរី ឌូស(Tori Duoos) ឌេនីស ខកឡេន(Denise Coghlan)



**DANMISSION**

អាសយដ្ឋាន: ផ្ទះលេខ 27 E1, ផ្លូវ 506/135 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌ ចំការមន ភ្នំពេញ

ទូរស័ព្ទ: (+៨៥៥) ៩២ ២១៤ ៤៣៦

អ៊ីម៉ែល: erj@danmission.dk

គេហទំព័រ: www.danmission.dk

**JRS Cambodia**

អាសយដ្ឋាន: មណ្ឌលមេត្តា ករុណា ភូមិកសិកម្ម សង្កាត់ ស្រះរំងៃ សៀមរាប ប្រអប់សំបុត្រ: ៩៣០៣៦

ទូរស័ព្ទ: (+៨៥៥)១២៤៨៨៩៥០, ៩២៣៣១៥០១

អ៊ីម៉ែល: denisecoghlan@yahoo.com.au

គេហទំព័រ: www.jrscambodia.org